# ស្ពានព្រែកតាមាក់បើកអោយយានយន្តធ្វើចរាចរណ៍ឆ្លងកាត់នៅវេលាម៉ោង ៧ ព្រឹក ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១០

លោកបណ្ឌិត ឃិត បុណ្ណា អនុរដ្ឋលេខាធិការ និងជានាយកគម្រោង បានអះអាងថា ក្រោយទទួលបានអនុសាសន៍របស់ **សម្តេចនាយករដ្ឋមន្ត្រី** នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១០ កន្លងមក ស្តីពីការអនុញ្ញាតអោយយានយន្តធ្វើចរាចរណ៍ឆ្លងកាត់ស្ពានព្រែកតាមាក់នេះមក មន្ត្រីបច្ចេកទេសក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះពិនិត្យលើទិដ្ឋភាពបច្ចេកទេស និងការសាងសង់ស្ពានខាងលើ និងបានសំណូមពរដល់ក្រុមហ៊ុនសៀងហៃ អោយជម្រុញការងារសាងសង់បង្ហើយរង្វង់មូលត្រើយខាងកើត និងផ្លូវតភ្ជាប់ប្រវែង ១០០ ម៉ែត្រ សងខាងរង្វង់មូល ។

អ្នកបច្ចេកទេសជាន់ខ្ពស់រូបនេះបានលើកឡើងថា តាមការចុះពិនិត្យជាក់ស្តែង ដំណើរការសាងសង់រង្វង់មូល និងផ្លូវតភ្ជាប់នេះបាននឹងបញ្ចប់ស្ថាពរ មុនដំណាច់ខែ កក្កដា ឆ្នាំ ២០១០។ កិច្ចការចុងក្រោយដែលសម្រួលសុវត្ថិភាពនៃការឆ្លងកាត់ទាំងត្រើយខាងកើត និងខាងលិច ជាមូលដ្ឋានបច្ចេកទេសបានបញ្ចប់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១០ និងផ្តល់លទ្ធភាពអោយចរាចរណ៍ឆ្លងកាត់ទៅតាមការគ្រោងទុក ។

ក្នុងគោលបំណងជួយសម្រាលទុក្ខលំបាក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតអោយ **ឯកឧត្តម ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បើកដាក់អោយប្រើប្រាស់ ។ លោក **ស្នួត សំបូរ** អនុរដ្ឋលេខាធិការ តំណាងអោយ **ឯកឧត្តមរដ្ឋមន្ត្រី** រួមជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ទាំងខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តកំពង់ចាម រាជធានីភ្នំពេញ ថ្នាក់ដឹកនាំ និងអ្នកបច្ចេកទេសក្រសួង មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តពាក់ព័ន្ធ ក៏ដូចអ្នកប្រើប្រាស់ផ្លូវ ស្ពាន បានចូលរួមពិធីចាត់ចែងបើកអោយយានយន្តគ្រប់ប្រភេទធ្វើចរាចរណ៍ឆ្លងកាត់ចាប់ពីម៉ោង ៧:00 នាទីព្រឹក ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១០ នេះតទៅ ។

លោក **ស្នួត សំបូរ** ក៏បានសំណូមពរអោយបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលចូលរួមក្នុងពិធីនេះថា នៅពេលដែលមានផ្លូវ ស្ពានល្អ សូមអោយបងប្អូនគ្រប់ៗរូបមានការបង្កើនស្មារតីប្រុងប្រយ័ត្នជានិច្ច ក្នុងការបញ្ជាយានយន្តគ្រប់ប្រភេទ និងសូមគោរពច្បាប់ចរាចរណ៍ផ្លូវគោកអោយបានខ្ជាប់ខ្ជួន ដោយពេលបើកបរម៉ូតូត្រូវពាក់មួកសុវត្ថិភាព និងបើកបររថយន្តត្រូវពាក់ខ្សែក្រវ៉ាត់គ្រប់ពេលវេលា សូមបងប្អូន កុំសេពគ្រឿងស្រវឹង ហើយបើកបរក្នុងទិសដៅបង្កើនការយកចិត្តទុកដាក់ការយល់ដឹងអំពីគត្តាហានិភ័យ ដែលបង្កគ្រោះថ្នាក់ដល់អាយុប្រជាជនគ្រប់ស្រទាប់ជាអ្នកប្រើប្រាស់ផ្លូវ ជាពិសេសអ្នកបើកបរម៉ូតូឱ្យបានយល់ដឹងអំពីអត្ថប្រយោជន៍ នៃការពាក់មួកសុវត្ថិភាព ដើម្បីចៀសវាងនូវគ្រោះថ្នាក់ចរាចរណ៍ ដែលកើតមានឡើងជាយថាហេតុ ។

ក្នុងការដាក់អោយដំណើរការចរាចរណ៍ឆ្លងកាត់ស្ពានព្រែកតាមាក់នេះ បងប្អូនប្រជាពលរដ្ឋគ្រប់ៗរូប រួមមាន ព្រះសង្ឃ លោកតា លោកយាយ បងប្អូនខ្មែរឥស្លាម យុវជន យុវនារីគ្រប់ស្រទាប់ មានសេចក្តីត្រេកអរជាពន្លឹក ហើយក៏បានសំដែងនូវគុណូបការៈដ៏ថ្លៃថ្លាបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានដាក់អោយអោយប្រើប្រាស់ស្ពានព្រែកតាមាក់នេះ ក្នុងការជួយសម្រាលទុក្ខលំបាក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌភូមិសាស្ត្រក៏ដូចទូទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ ។